## សិក្ខាសាលាស្តីពី

## ការផ្សព្វផ្សាយអំពីគោលការណ៍ណែនាំស្តីពីការប្រើប្រាស់ទម្រង់របាយការណ៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងប្រព័ន្ធលំហូររបាយការណ៍ក្រោមក្របខ័ណ្ឌផែនការអនុវត្តរយៈពេលបីឆ្នាំដំបូង (២០១១-២០១៣) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(ផ.អ.៣)

រាជធានីភ្នំពេញ ថ្ងៃទី ៤-៥ ខែតុលា ឆ្នាំ២០១១ , នៅសណ្ឋាគារភ្នំពេញ

.....................................................

**សុន្ទរកថាបិទ**

**ឯកឧត្តម ង៉ាន់ ចំរើន អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន**

**ក្រសួងមហាផ្ទៃ និងជាអនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

**សូមគោរព :**

- លោក លោកស្រីដែលជាទីប្រឹក្សា និងមន្ត្រីនៃលេខាធិការដ្ឋាន គ.ជ.អ.ប
- លោក លោកស្រី តំណាងឱ្យអនុកម្មវិធីនានារបស់ ផ.អ.៣
- លោក លោកស្រី តំណាងឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងទីប្រឹក្សាតាមដាន និងត្រួតពិនិត្យរាជធានី ខេត្ត
- លោក លោកស្រី តំណាងឱ្យកម្មវិធីសិទ្ធិកុមារ នៃអង្គការយូនីសេហ្វ ប្រចាំរាជធានីភ្នំពេញ និងតាមតំបន់គោលដៅ **ជាទីគោរពរាប់អាន !**

ថ្ងៃនេះ ខ្ញុំមានកិត្តិយស និងមានសេចក្តីសោមនស្សរីករាយ ដែលបានចូលរួមក្នុងពិធីបិទសិក្ខាសាលាផ្សព្វផ្សាយអំពីគោលការណ៍ណែនាំស្តីពីការប្រើប្រាស់ទម្រង់របាយការណ៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងប្រព័ន្ធលំហូររបាយការណ៍ ក្រោមក្របខ័ណ្ឌ ផ.អ.៣។

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណ និងសម្តែងនូវការកោតសរសើរដល់អស់លោក លោកស្រីទាំងអស់គ្នាដែលបានយកចិត្តទុកដាក់ និងបានចូលរួមយ៉ាងសកម្ម នៅក្នុងការពិភាក្សាគ្នាអំពីទម្រង់របាយការណ៍ និងអំពីការបង្កើតសូចនាកររួមមួយ ផ្អែកតាមផែនការសកម្មភាព និងថវិកា ឆ្នាំ២០១១ ដែលរាជធានី ខេត្តបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប ក្រោមក្របខ័ណ្ឌ **ផ.អ.៣** (២០១១-២០១៣) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ការបង្កើតទម្រង់របាយការណ៍ស្តង់ដាររួមនេះ មាន

សារៈសំខាន់ណាស់ ដើម្បីឱ្យលេខាធិការដ្ឋានអាចបូកសរុប និងសំយោគរបាយការណ៍ពីគ្រប់រាជធានី ខេត្តបានសម្រាប់ប្រើប្រាស់ជាបណ្តោះអាសន្ន នៅឆ្នាំ២០១១ នេះ។

ដើម្បីធានានូវប្រសិទ្ធភាពនៃការតាមដាន និងវាយតម្លៃ ជាពិសេសក្នុងការរៀបចំរបាយការណ៍ការអនុវត្តផែនការសកម្មភាព និងថវិកាតាមឆ្នាំនីមួយៗ លេខាធិការដ្ឋាន គ.ជ.អ.ប បានកំពុងរៀបចំប្រព័ន្ធទិន្នន័យកុំព្យូទ័រដើម្បីកត់ត្រាការអនុវត្តទាំងនេះ ហើយសង្ឃឹមថានឹងត្រូវដាក់ឱ្យប្រើប្រាស់នៅឆ្នាំ២០១២ ដោយសារតែផែនការសកម្មភាព និងថវិកាឆ្នាំ២០១១នេះ មានលក្ខណៈស្មុគស្មាញ និងពិបាកក្នុងការបង្កើតសូចនាករស្តង់ដាររួមមួយ សម្រាប់ការតាមដាន និងវាយតម្លៃដែលពាក់ព័ន្ធនឹងកម្រិតសកម្មភាព និងធាតុចេញ។ ដោយផ្អែកទៅលើបទពិសោធន៍នេះ លេខាធិការដ្ឋានគ.ជ.អ.ប បានកំពុងតែរៀបចំពិនិត្យមើលឡើងវិញ ដើម្បីកសាងផែនការសកម្មភាព និងថវិកា ឆ្នាំ២០១២ ដោយធានាឱ្យមានការចូលរួមពេញលេញពីរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួង និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពនៃការអនុវត្ត និងភាពជាក់លាក់សម្រាប់ការតាមដាន និងវាយតម្លៃ។

ផ.អ.៣ បានកំណត់នូវក្របខ័ណ្ឌតាមដាន និងវាយតម្លៃមួយដ៏ទូលំទូលាយសម្រាប់ការអនុវត្តកម្មវិធី និងលទ្ធផលនៃការអនុវត្តកម្មវិធី។ ដើម្បីអនុវត្តក្របខ័ណ្ឌតាមដាន និងវាយតម្លៃនេះ គឺតម្រូវឱ្យបង្កើតនូវឧបករណ៍សម្ភារៈ និងបច្ចេកទេសជាច្រើនទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងគោលដៅកសាងប្រព័ន្ធតាមដាន និងវាយតម្លៃ មួយដែលមានលក្ខណៈជាស្ថាប័ន ដែលបញ្ហានេះធ្វើឱ្យមានភាពយឺតយ៉ាវនៅក្នុងការរៀបចំប្រព័ន្ធតាមដាន និងវាយតម្លៃនៅថ្នាក់ជាតិ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយសារតែកិច្ចការទាំងអស់នេះមានលក្ខណៈបច្ចេកទេសស្មុគស្មាញ និងត្រូវការពេលវេលាយូរ ជាពិសេសទាមទារឱ្យមានការសិក្សាពិគ្រោះយោបល់ជាប្រព័ន្ធ ការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់ និងការយកចិត្តទុកដាក់ និងជម្រុញពីថ្នាក់ដឹកនាំ *ដូចដែលលោកប្រធានផ្នែកតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយរបស់លេខាធិការដ្ឋានបានគូសបញ្ជាក់ក្នុងពិធីបើកសិក្ខាសាលារួចមកហើយ*។ឧទាហរណ៍ជាក់ស្តែងគ្រាន់តែនៅក្នុងការបង្កើតទម្រង់របាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ព្រមទាំងប្រព័ន្ធលំហូររបាយការណ៍នេះ គឺយើងបានចំណាយពេល វេលាជាច្រើនខែ ទាំងក្នុងដំណើរការរៀបចំ ការសិក្សាពិគ្រោះយោបល់ និងការកែលំអ។

តាមការពិត យើងមានបទពិសោធន៍ច្រើនក្នុងបង្កើត និងការអនុវត្តការតាមដាន និងវាយតម្លៃជាលក្ខណៈកម្មវិធី ក្នុងវិស័យកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ជិតមួយទសវត្សរ៍កន្លងមកនេះ ដែលអស់លោក លោកស្រីបានដឹងទាំងអស់គ្នាថា រដ្ឋបាលឃុំ សង្កាត់មានប្រព័ន្ធតាមដាន និងវាយតម្លៃជាក់លាក់សម្រាប់អនុវត្ត ដូចជាប្រព័ន្ធទិន្នន័យសម្រាប់រៀបចំផែនការអភិវឌ្ឍន៍ (ស៊ី.ឌី.ភី.ឌី) និងប្រព័ន្ធទិន្នន័យនៃការអនុវត្តគម្រោងអភិវឌ្ឍន៍ (ភី.អាយ.ឌី)ដែលប្រព័ន្ធទិន្នន័យទាំងនេះ បានជួយយើងយ៉ាងច្រើនក្នុងការតាមដាន និងវាយតម្លៃលើការងារឃុំ សង្កាត់។ ការបង្កើតប្រព័ន្ធទិន្នន័យសម្រាប់កត់ត្រាការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ និងការអភិវឌ្ឍនានានៅតាមរដ្ឋបាល

ថ្នាក់ក្រោមជាតិ មិនត្រឹមតែមានអត្ថប្រយោជន៍សម្រាប់ការតាមដាន និងវាយតម្លៃប៉ុណ្ណោះទេ គឺវាមានសារៈសំខាន់ដ៏ជ្រាលជ្រៅដែលអាចជួយឱ្យអ្នកសិក្សាស្រាវជ្រាវនានាយកទៅវិភាគ ដើម្បីផ្តល់នៅព័ត៌មានយុទ្ធសាស្ត្រសម្រាប់ជម្រើសគោលនយោបាយនៃការអភិវឌ្ឍ (ឧទាហរណ៍ លទ្ធផលដែលបានមកពីការវិភាគតាមបែបស្ថិតិវិទ្យារបស់ទីប្រឹក្សាជាតិនៃផ្នែកតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ដែលបានប្រើប្រាស់ទិន្នន័យពីប្រព័ន្ធទិន្នន័យព័ត៌មានគម្រោងឃុំ សង្កាត់ និងពិន្ទុភាពក្រីក្ររបស់ក្រសួងផែនការ បានបង្ហាញថានៅក្នុងរវាងកំឡុងឆ្នាំ២០០៥ ដល់ឆ្នាំ២០១០ មូលនិធិវិនិយោគដែលបានចំណាយជាមធ្យមចំនួន១៤៣១៧ ដុល្លារសម្រាប់មួយឃុំ សង្កាត់ក្នុងមួយឆ្នាំ បានរួមចំណែកកាត់បន្ថយពិន្ទុភាពក្រីក្រតាមឃុំ សង្កាត់ចំនួន២,៩ ភាគរយជាមធ្យមក្នុងមួយឆ្នាំសម្រាប់មួយឃុំ សង្កាត់)។ លទ្ធផលនេះ បានផ្តល់នូវមោទនភាពដល់រាជរដ្ឋាភិបាល អ្នកអនុវត្តនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍ដែលពាក់ព័ន្ធដែលបានធ្វើការវិនិយោគ តាមរយៈប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ។

ចំពោះក្របខណ្ឌតាមដាន និងវាយតម្លៃ នៃផ.អ.៣ គឺផ្តោតទាំងទៅលើការគ្រប់គ្រង ការអភិវឌ្ឍស្ថាប័ន និងគម្រោងអភិវឌ្ឍន៍នានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ដូច្នេះ យើងត្រូវការប្រព័ន្ធតាមដាន និងវាយតម្លៃនៅរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាល ក្រុង ស្រុក ខណ្ឌ ដែលស្រដៀងទៅនឹងប្រព័ន្ធរបស់រដ្ឋបាលឃុំ សង្កាត់។មានន័យថាយើងត្រូវកសាងប្រព័ន្ធតាមដាន និងវាយតម្លៃ សម្រាប់រដ្ឋបាលរាជធានី ខេត្ត ដើម្បីឱ្យរាជធានី ខេត្តអាចអនុវត្ត និងគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រមទាំងមានប្រព័ន្ធតាមដាន និងវាយតម្លៃនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីអាចអនុវត្ត និងធានាឱ្យរដ្ឋបាលក្រុងស្រុក ខណ្ឌ ជួយគាំទ្រដល់រដ្ឋបាលឃុំ សង្កាត់ ស្របតាមច្បាប់រៀបចំអង្គការ។ និន្នាការថ្មីនេះ គឺជាបញ្ហាប្រឈមមុខដ៏ស្មុគស្មាញមួយសម្រាប់យើងទាំងអស់គ្នា។ ក្នុងន័យនេះ ទាមទារឱ្យយើងអនុវត្តបណ្តើរ និងដកបទពិសោធន៍បណ្តើរ ដើម្បីធ្វើការកែសម្រួល។

ទោះជាយ៉ាងណាក៏ដោយ ដោយមានការប្តេជ្ញាចិត្តខ្ពស់ពីថ្នាក់ដឹកនាំ និងការខិតខំប្រឹងប្រែងរបស់លោក លោកស្រីទាំងអស់គ្នា ខ្ញុំជឿជាក់យ៉ាងមុតមាំថា យើងនឹងអាចសម្រេចបាននូវគោលដៅនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ជាពិសេសការបង្កើតឱ្យមានប្រព័ន្ធតាមដាន និងវាយតម្លៃ មួយដែលមានលក្ខណៈជាស្ថាប័ននៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យយើងអាចផ្តល់ព័ត៌មានយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពដល់អ្នកអនុវត្ត ថ្នាក់ដឹកនាំ និងអ្នកធ្វើគោលនយោបាយនានា។

លោក លោកស្រី ដែលជាសមាជិក សមាជិកា ជ្រាបថា !

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមចែករំលែកនូវព័ត៌មានអំពីការរីកចម្រើនក្នុងការអនុវត្តកំណែទម្រង់ ជាពិសេសការរៀបចំគោលនយោបាយ និងគោលការណ៍នានាដែលគាំទ្រដល់ការអនុវត្តច្បាប់រៀបចំអង្គការ។ រហូតមកដល់ពេលនេះលេខាធិការដ្ឋានកំពុងសិក្សាកែសម្រួលរចនាសម្ព័ន្ធរបស់ខ្លួនឱ្យបានស្របតាមច្បាប់រៀបចំអង្គការ និងបានរៀបចំ និងកែ

សម្រួលអនុក្រឹត្យស្ដីពីមូលនិធិក្រុង ស្រុក អនុក្រឹត្យស្ដីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក និងលិខិតបទដ្ឋានមួយចំនួនទៀត ដើម្បីធានាឱ្យរដ្ឋបាលនេះមានប្រភពធនធានក្នុងការអភិវឌ្ឍ ហើយសង្ឃឹមថានឹងដាក់ជូនកិច្ចប្រជុំ គ.ជ.អ.ប នាពេលខាងមុខ។ ទន្ទឹមនឹងនេះដែរ ខ្ញុំសូមគូសបញ្ជាក់បន្ថែមអំពីការរៀបចំរបាយការណ៍ក្រោមក្របខណ្ឌ ផ.អ.៣ ត្រូវតែអនុវត្តទៅតាមលិខិតលេខ១១៧ សណន/គ.ជ.អ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១១ ស្ដីពីគោលការណ៍ណែនាំស្ដីពីការប្រើប្រាស់ទម្រង់របាយការណ៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងប្រព័ន្ធលំហូររបាយការណ៍ ក្រោមក្របខ័ណ្ឌផែនការអនុវត្តរយៈពេលបីឆ្នាំដំបូង តែមួយប៉ុណ្ណោះ។

មុននឹងបញ្ចប់នេះ ខ្ញុំសូមស្នើឱ្យលោក លោកស្រី ដែលមកពីទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត និងទីប្រឹក្សាទាំងអស់ ខិតខំប្រឹងប្រែងរៀបចំប្រមូលទិន្នន័យសម្រាប់រៀបចំរបាយការណ៍ប្រចាំឆ្នាំ ២០១១ និងផ្សព្វផ្សាយបន្តដល់ស្ថាប័ន ឬអង្គភាពដែលពាក់ព័ន្ធនៅក្នុងរាជធានី ខេត្ត ជាពិសេសយកទៅផ្សព្វផ្សាយបន្តដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងបន្តការគាំទ្រដល់រដ្ឋបាលនេះ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព និងគុណភាពនៃរបាយការណ៍នេះ។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោក លោកស្រីទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការចូលរួមសិក្ខាសាលានេះ និងសូមប្រសិទ្ធពរជ័យមហាបវរប្រសើរជូនលោក លោកស្រីទាំងអស់ទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមប្រកាសបិទសិក្ខាសាលាស្ដីពីការផ្សព្វផ្សាយអំពីគោលការណ៍ណែនាំស្ដីពីការប្រើប្រាស់ទម្រង់របាយការណ៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងប្រព័ន្ធលំហូររបាយការណ៍ ក្រោមក្របខ័ណ្ឌផែនការអនុវត្តរយៈពេលបីឆ្នាំដំបូង (២០១១-២០១៣) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (ផ.អ.៣) ចាប់ពីពេលនេះតទៅ។

**សូមអរគុណ !**